雲南日報 YUNNAN DAILY PRESS GROUP 云南日报报业集团 No.137

# ប្រទេសចិន-ខេត្តយូនណាន

រស្មីកម្ពុជា ប្រចាំថ្ងៃ

YUNNAN DAILY PRESS GROUP english.yunnan.cn

ឆ្នាំទី 25 លេខ 7521 ថ្ងៃសុក្រ ទី29 ខែធ្នូ ឆ្នាំ 2017

## ផ្លូវដែកចិន-ថៃផ្តល់ផលប្រយោជន៍ដល់តំបន់អាស៊ីអាគ្នេយ៍ទាំងមូល

***ដោយ ទឹង ជី និង សួន ក្វាងយ៉ុង (កាសែតប្រជាជនដេលី)***

នៅថ្ងៃទី២១ ខែធ្នូ ពិធីបើកការដ្ឋានសាងសង់ផ្លូវដែកចិន-ថៃដំណាក់កាលទី១បានប្រារព្ធនៅស្រុកបាឃុងនៃខេត្តនគររាជសីមាប្រទេសថៃ ។ លោក ប្រាយុទ្ធ ចាន់អូចា នាយករដ្ឋមន្ត្រីថៃបានអញ្ជើញចូលរួមក្នុងពិធីបើកការដ្ឋានសាងសង់នេះ ។ លោក លី ខឺឈាំង នាយករដ្ឋមន្ត្រីចិនបានផ្ញើលិខិតអបអរសាទរចំពោះការបើកការដ្ឋានសាងសង់ផ្លូវដែកចិន-ថៃ ។

លោក ប្រាយុទ្ធ ចាន់អូចា មានប្រសាសន៍ថា គម្រោងសាងសង់ផ្លូវដែកចិន-ថៃមិនគ្រាន់តែនឹងជំរុញការអភិវឌ្ឍសេដ្ឋកិច្ចនៃប្រទេសថៃប៉ុណ្ណោះទេ ថែមទាំងនឹងជំរុញការតភ្ជាប់គ្នាក្នុងតំបន់ ។ ខ្សែរថភ្លើងនេះបានតភ្ជាប់ប្រទេសថៃទៅនឹងបណ្តាប្រទេសជិតខាងនានា ហើយនឹងក្លាយជាផ្នែកមួយនៃបណ្តាញគមនាគមន៍ "ខ្សែក្រវាត់និងផ្លូវ"។វានឹងជំរុញឱ្យប្រទេសថៃក្លាយទៅជាមជ្ឈមណ្ឌលគមនាគមន៍ និងឡូជីស្ទីកអាស៊ាន ព្រមទាំងនឹងអាចធ្វើឱ្យប្រទេសថៃទទួលបានការរីកចម្រើនកាន់តែច្រើន និងក្លាយទៅជាប្រទេស ដែលមានចំណូលកម្រិតខ្ពស់។



*ពិធីចុះបឋមសិលាបើកការ ដ្ឋានដំណាក់កាលទីមួយនៃកំណាត់ផ្លូវដែកល្បឿនលឿនចិន-ថៃ (រូបថតដោយ Xinhua )*

លោក លី ខឺឈាំង បានថ្លែងក្នុងលិខិតអបអរសាទរថា គម្រោងសាងសង់ផ្លូវដែកចិន-ថៃជាគម្រោងសំខាន់សម្រាប់ជំរុញការកសាង "ខ្សែក្រវាត់និងផ្លូវ" ព្រមទាំងចូលរួមចំណែកក្នុងការពង្រឹងកិច្ចសហប្រតិបត្តិការសមត្ថភាពផលិតរវាងប្រទេសទាំងពីរ ។ គម្រោងនេះនឹងជំរុញការសាងសង់ហេដ្ឋារចនាសម្ព័ន្ធ និងការតភ្ជាប់គ្នាទាំងក្នុងប្រទេសថៃ និងក្នុងកម្រិតតំបន់ ហើយនឹងជំរុញការអភិវឌ្ឍសេដ្ឋកិច្ចជានិរន្តរភាពរបស់ប្រទេសថៃ និងការអភិវឌ្ឍនៃតំបន់ ព្រមទាំងជួយលើកកម្ពស់កម្រិតជីវភាពរស់នៅរបស់ប្រជាជន ។ ខ្ញុំសង្ឃឹមថា ភាគីទាំងពីរនឹងអាចរក្សាកិច្ចសហប្រតិបត្តិការស្អិតល្មួតក្នុងការបញ្ចប់ការសាងសង់ដោយជោគជ័យនូវគម្រោងផ្លូវដែកចិន-ថៃ ដំណាក់កាលទី១និងបន្តជំរុញការអនុវត្តគម្រោងសាងសង់ដំណាក់កាល ទី២ដើម្បីតភ្ជាប់នូវខ្សែរថភ្លើងចិន-ថៃ និងខ្សែរថភ្លើងចិន-ឡាវក្នុងពេលឆាប់ៗ។

ផ្លូវដែកចិន-ថៃជាគម្រោងសំខាន់មួយដែលអាចផ្តល់ផលប្រយោជន៍ជាក់ស្តែងដល់តំបន់អាស៊ីអាគ្នេយ៍ទាំងមូល ។ លោក អាខុម ថឹមពីយ៉ាផៃសិទ្ធ រដ្ឋមន្ត្រីក្រសួងគមនាគមន៍ថៃមានប្រសាសន៍ថា គម្រោងសាងសង់ផ្លូវដែកចិន-ថៃមិនគ្រាន់តែនឹងអាចជំរុញការអភិវឌ្ឍនៃតំបន់ឦសានប្រទេសថៃប៉ុណ្ណោះទេ ហើយគម្រោងដំណាក់កាលទី២ នឹងអាចតភ្ជាប់ខ្សែរថភ្លើងនេះទៅនឹងខេត្តណងខៃ ដែលមានទីតាំងស្ថិតនៅជាប់នឹងក្រុងវៀងចន្ទន៍ប្រទេសឡាវ ។ ជាពិសេសវានឹងអាចតភ្ជាប់ទៅនឹងកំណាត់ម៉ាកទីង-វៀងចន្ទន៍នៃផ្លូវដែកចិន-ឡាវដែលអាចផ្តល់ផលប្រយោជន៍ជាក់ស្តែងដល់ប្រទេសថៃ និងបណ្តាប្រទេសជិតខាងនានា ។

គម្រោងផ្លូវដែកចិន-ថៃដំណាក់កាលទី១មានប្រវែងសរុប២៥២,៣ គីឡូម៉ែត្រ ដោយមានចំណតចំនួន៦ ។ បន្ទាប់ពីបញ្ចប់ការសាងសង់ជាស្ថាពររថភ្លើងអាចធ្វើដំណើរក្នុងល្បឿន២៥០ គីឡូម៉ែត្រក្នុងមួយម៉ោងតាមខ្សែរថភ្លើងនេះ ដែលនឹងអាចកាត់បន្ថយរយៈពេលនៃការធ្វើដំណើរពីក្រុងបាងកកទៅខេត្តនគររាជសីមាពី៤-៦ម៉ោងដល់មួយម៉ោងកន្លះ ៕

## គម្រោងគំរូអំពីការកាត់បន្ថយភាពក្រីក្រ ដែលផ្តល់ជំនួយដោយប្រទេសចិន ចាប់ដំណើរការអនុវត្តជាផ្លូវការ



*ពិធីសម្ពោធដំណើរការអនុវត្ត នូវគម្រោងគំរូអំពីការកាត់បន្ថយភាពក្រីក្រ (រូបថត ដោយ Ding Feng )*

នៅថ្ងៃទី២១ ខែធ្នូ គម្រោងគំរូអំពីការកាត់បន្ថយភាពក្រីក្រ ដែលផ្តល់ជំនួយដោយប្រទេសចិននោះបានបើកសម្ពោធជាផ្លូវការនៅខេត្តកណ្តាលនៃប្រទេសកម្ពុជា។

គម្រោងនេះមានរយៈពេលអនុវត្តន៍៣ឆ្នាំ ។ តាមគម្រោងគំរូនេះប្រទេសចិននិងកម្ពុជានឹងអាចបង្កើតកិច្ចសហប្រតិបត្តិការស្អិតល្មួតក្នុងការកាត់បន្ថយភាពក្រីក្រតាមការណែនាំពីរដ្ឋាភិបាលនៃប្រទេសទាំងពីរ និងមានការចូលរួមពីមហាជនដ៏ច្រើន ។ ភាគីទាំងពីរនឹងរួមគ្នាជំរុញការកាត់បន្ថយភាពក្រីក្រនៅភូមិចំនួនពីរនៅខេត្តកណ្តាលនៃប្រទេសកម្ពុជា ដោយប្រើប្រាស់បទពិសោធន៍នៃការកាត់បន្ថយភាពក្រីក្ររបស់ប្រទេសចិនរួមមានគោលនយោបាយអំពីការកាត់បន្ថយភាពក្រីក្រនៃភូមិទាំងមូល និងការកាត់បន្ថយភាពក្រីក្រដោយតម្រង់ទិស ដើម្បីបំពេញតម្រូវការរបស់ប្រជាជនខ្មែរតាមស្ថានភាពជាក់ស្តែង ។ ប្រទេសចិននឹងផ្តល់ជំនួយដល់ប្រជាជនខ្មែរ ដែលរស់នៅក្នុងភូមិទាំងពីរក្នុងការសាងសង់ផ្លូវថ្នល់សាងសង់ប្រព័ន្ធផ្គត់ផ្គង់ទឹកកែលម្អលក្ខខណ្ឌនៃការរស់នៅបង្កើតមជ្ឈមណ្ឌលសុខាភិបាល និងមជ្ឈមណ្ឌលសិក្សារៀនសូត្រជាដើម ព្រមទាំងជួយប្រជាកសិករតាមតំបន់ក្នុងការដាំដំណាំ និងចិញ្ចឹមសត្វ ហើយចាត់បញ្ជូនអ្នកជំនាញការចិនឱ្យទៅផ្តល់ការបណ្តុះបណ្តាលបច្ចេកទេសដល់ប្រជាកសិករ ។ តាមរយៈការអនុវត្តគោលនយោបាយកាត់បន្ថយភាពក្រីក្ររបស់ប្រទេសចិនតំបន់ជនបទកម្ពុជានឹងអាចបញ្ចេញកម្លាំងរស់រវើកកាន់តែច្រើន ។ គួរបញ្ជាក់ថា គម្រោងនេះនឹងផ្តល់ផលប្រយោជន៍ជាក់ស្តែងដល់ប្រជាជនខ្មែរ៨៨៦គ្រួសារសរុបមានជាង៣.៩០០នាក់ ។

សព្វថ្ងៃ មន្ទីរអន្តោប្រវេសន៍និងកាត់បន្ថយភាពក្រីក្រខេត្តស៊ីឈួនប្រទេសចិនបានចាត់បញ្ជូនអ្នកជំនាញការចិនទៅធ្វើការនៅប្រទេសកម្ពុជា ហើយបានរួមសហការគ្នាជាមួយក្រសួងអភិវឌ្ឍន៍ជនបទកម្ពុជាក្នុងការបង្កើតការិយាល័យអនុវត្តន៍គម្រោងចិន-កម្ពុជា ដើម្បីជំរុញការអនុវត្តគម្រោងនេះឱ្យទទួលបានជោគជ័យ ៕

## ទីស្នាក់ការពាណិជ្ជកម្មខេត្តយូនណានប្រចាំនៅរាជធានីភ្នំពេញ: បង្កើតស្ពាននៃកិច្ចសហប្រតិបត្តិការយូនណាន-កម្ពុជា

***ដោយ ឈឹន ឈួងយី***

នៅថ្ងៃទី២១ ខែធ្នូ កិច្ចប្រជុំពិគ្រោះពិភាក្សាពាណិជ្ជកម្មអំពីការប្រកួតរថយន្តអន្តរជាតិ "ខ្សែក្រវាត់និងផ្លូវ: ខេត្តយូនណានដ៏ចម្រុះពណ៌" ឆ្នាំ២០១៧បានប្រារព្ធនៅរាជធានីភ្នំពេញនៃព្រះរាជាណាចក្រកម្ពុជា ។ កិច្ចប្រជុំនេះរៀបចំដោយទីស្នាក់ការពាណិជ្ជកម្មខេត្តយូនណានប្រចាំនៅរាជធានីភ្នំពេញ ។

ទីស្នាក់ការពាណិជ្ជកម្ម (សហគ្រាស)ខេត្តយូនណានប្រចាំនៅរាជធានីភ្នំពេញត្រូវបានបង្កើតឡើងនៅថ្ងៃទី៦ ខែមេសា ឆ្នាំ២០១២ ដោយក្រុមហ៊ុនវិនិយោគសំណង់ខេត្តយូនណានគ្រុប ។ ទីស្នាក់ការពាណិជ្ជកម្មខេត្តយូនណានប្រចាំនៅរាជធានីភ្នំពេញបានចាត់ទុកការជួយសម្របសម្រួលធ្វើជាច្រកផ្សព្វផ្សាយផ្តល់សេវាកម្ម និងរក្សាសិទ្ធិជាភារកិច្ចសំខាន់ ដើម្បីបង្កើតជាស្ពានមួយខ្សែសម្រាប់ជំរុញការទាក់ទងគ្នារវាងសហគ្រាសខេត្តយូនណាននៅប្រទេសកម្ពុជាជាមួយរាជរដ្ឋាភិបាលកម្ពុជាស្ថានទូតប្រទេសចិនប្រចាំនៅប្រទេសកម្ពុជានិងការិយាល័យពាណិជ្ជកម្មនៃស្ថានទូតប្រទេសចិនប្រចាំនៅប្រទេសកម្ពុជាជាដើមព្រមទាំងធ្វើការសម្របសម្រួល និងផ្តល់សេវាកម្មដល់សហគ្រាសខេត្តយូនណាន ដែលធ្វើអាជីវកម្មនៅប្រទេសកម្ពុជាបង្កើនការយល់ដឹងគ្នាទៅវិញទៅមក និងជំរុញការអភិវឌ្ឍនៃសហគ្រាសខេត្តយូនណាន និងប្រទេសកម្ពុជា ។

លោក លី សាវឈួន ប្រធានទីស្នាក់ការពាណិជ្ជកម្មខេត្តយូនណានប្រចាំនៅរាជធានីភ្នំពេញនិងជាអគ្គនាយកនៃសាខាក្រុមហ៊ុនប្រចាំនៅរាជធានីភ្នំពេញ នៃក្រុមហ៊ុនវិនិយោគសំណង់ខេត្តយូនណាន គ្រុប បានបញ្ជាក់ថា សព្វថ្ងៃទីស្នាក់ការពាណិជ្ជកម្មយើងខ្ញុំបានដំណើរការយ៉ាងរលូន ។ តាំងពីឆ្នាំ ២០១២ មក ទីស្នាក់ការពាណិជ្ជកម្មយើងខ្ញុំបានទទួលគណៈប្រតិភូសាលាខេត្តយូនណានចំនួន២៩ ជំរុញឱ្យសហគ្រាសខេត្តយូនណានចំនួន៣ ទៅធ្វើវិនិយោគនៅប្រទេសកម្ពុជា និងផ្តល់សេវាកម្មដល់សហគ្រាសខេត្តយូនណានចំនួន៨២ ដែលទៅសិក្សាពីឱកាសវិនិយោគនៅប្រទេសកម្ពុជា ។

ទីស្នាក់ការពាណិជ្ជកម្មខេត្តយូនណានប្រចាំនៅរាជធានីភ្នំពេញយកចិត្តទុកដាក់ចំពោះការអភិវឌ្ឍទំនាក់ទំនង មិត្តភាពជាមួយស្ថាប័នរដ្ឋាភិបាលកម្ពុជា ហើយខិតខំជំរុញការធ្វើកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ច និងពាណិជ្ជកម្មរវាងខេត្តយូនណាន និងប្រទេសកម្ពុជា ដើម្បីបង្កើតជាស្ពានមួយខ្សែសម្រាប់ពង្រឹងកិច្ចសហប្រតិបត្តិការរវាងសហគ្រាសខេត្តយូនណាន និងប្រទេសកម្ពុជា ។ លោក លី សាវឈួន បន្តទៀតថា ទីស្នាក់ការពាណិជ្ជកម្មខេត្តយូនណានប្រចាំនៅរាជធានីភ្នំពេញបានបង្កើតយន្តការទំនាក់ទំនងរយៈពេលវែងជាមួយស្ថាប័នគ្រប់ជាន់ថ្នាក់នៃរាជរដ្ឋាភិបាលកម្ពុជា រួមមានក្រសួងមហាផ្ទៃ ក្រសួងពាណិជ្ជកម្មក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈនិងក្រសួងឧស្សាហកម្ម និងសិប្បកម្ម ជាដើម ៕

## ពិព័រណ៍ចិន-អាស៊ីខាងត្បូង លើកទី៥ នឹងរៀបចំនៅក្រុងគុនមីងនា ខែមិថុនា ឆ្នាំ ២០១៨

***ដោយ ទូ ជឹង***

ពេលថ្មីៗនេះ ក្រសួងពាណិជ្ជកម្មចិននិងសាលារដ្ឋបាលប្រជាជនខេត្តយូនណាន បានរួមគ្នារៀបចំសន្និសីទសារព័ត៌មាននៅក្រុងប៉េកាំង និងបានប្រកាសព័ត៌មានជាសាធារណៈថា ពិព័រណ៍ចិន-អាស៊ីខាងត្បូងលើកទី ៥ និងពិព័រណ៍ផលិតផលនាំចេញនាំចូលក្រុងគុនមីងប្រទេសចិនលើកទី ២៥ នឹងរៀបចំនៅក្រុងគុនមីង នៃខេត្តយូនណាន ក្នុងអំឡុងពេលពីថ្ងៃទី ១២-១៨ ខែមិថុនា ឆ្នាំ ២០១៨ ។

ពិព័រណ៍នេះនឹងរៀបចំក្រោមប្រធានបទ"ចូលរួមកសាងខ្សែក្រវាត់និងផ្លូវ ជំរុញកិច្ចសហប្រតិបត្តិការឈ្នះ-ឈ្នះ" ហើយមានពន្លាពិព័រណ៍ចំនួន ១៩ រួមមានពន្លាពិព័រណ៍ប្រទេស កិត្តិយសពន្លាពិព័រណ៍អាស៊ីខាងត្បូង ពន្លាពិព័រណ៍អាស៊ីអាគ្នេយ៍ ពន្លាពិព័រណ៍ក្រៅប្រទេស ពន្លាពិព័រណ៍ក្នុងស្រុកពន្លាពិព័រណ៍ទេសចរណ៍ ពន្លាពិព័រណ៍កសិកម្ម និងពន្លាពិព័រណ៍សម្ភារៈថ្មីជាដើម សរុបមានស្តង់ពិព័រណ៍ប្រមាណ ៨.៥០០ ស្តង់ និងផ្ទៃក្រឡាតាំងពិព័រណ៍ ១៩ ម៉ឺនម៉ែត្រការ៉េ ។ ទន្ទឹមនឹងនេះ ម្ចាស់រៀបចំពិព័រណ៍នឹងដាក់តាំងបង្ហាញនូវផលិតផលពិសេសនៃប្រទេសផ្សេងៗ និងរៀបចំសកម្មភាពផ្សព្វផ្សាយនិងធ្វើបទបង្ហាញអំពីការវិនិយោគនិងពាណិជ្ជកម្ម ព្រមទាំងវេទិកាធុរកិច្ចចិន-អាស៊ីខាងត្បូង វេទិកាធុរកិច្ចចិន-អាស៊ីអាគ្នេយ៍ វេទិកាឃ្លាំងគំនិតចិន-អាស៊ីខាងត្បូង និងអាស៊ីអាគ្នេយ៍ វេទិកានៃកិច្ចសហប្រតិបត្តិការថ្នាក់ខេត្តចិន-អាមេរិក និងសកម្មភាពសប្តាហ៍ក្រុងគុនមីង អំពីកិច្ចសហប្រតិបត្តិការឡានឆាង-មេគង្គជាដើម ។ ក្នុងឱកាសនោះ ស្ថាប័នរដ្ឋាភិបាល និងសភាពាណិជ្ជកម្មនៃបណ្តាប្រទេសពាក់ព័ន្ធនឹងចូលរួមធ្វើបទបង្ហាញអំពីគោលនយោបាយ បរិយាកាស និងគម្រោងវិនិយោគ ដើម្បីទាក់ទាញអ្នកវិនិយោគចិនឱ្យបានកាន់តែច្រើន ។ ពិព័រណ៍នេះនឹងអាចជំរុញឱ្យបណ្តាប្រទេសពាក់ព័ន្ធសម្រេចបាននូវការឯកភាពគ្នាលើវិស័យកាន់តែច្រើន និងប្រមូលផ្តុំនូវកម្លាំងពីភាគីនានា ដើម្បីជំរុញការអភិវឌ្ឍ ៕

## ប្រទេសចិនផលិតដោយជោគជ័យនូវរថភ្លើងក្រោមដី ដែលមានស្តង់ដារខ្ពស់ជាងគេក្នុងការការពារអគ្គិភ័យ



*(រូបថតដោយ Xinhua )*

នៅថ្ងៃទី ២១ ខែធ្នូ រថភ្លើងក្រោមដីក្រុមទី ១ ដែលសិក្សាស្រាវជ្រាវដោយក្រុមហ៊ុនផលិតរថភ្លើង ស៊ីហ្វាង ក្រុងឈីងតាវនៃក្រុមហ៊ុនផលិតរថភ្លើងចិនគ្រុប សម្រាប់ដាក់ឱ្យប្រើប្រាស់តាមខ្សែរថភ្លើងក្រោមដីក្នុងតំបន់ហុងកុង បានត្រូវផលិតដោយជោគជ័យ ។ គម្រោងនេះជាគម្រោងផលិតរថភ្លើងក្រោមដីដែលមានទ្រង់ទ្រាយធំជាងគេក្នុងប្រទេសចិន ហើយក៏ជារថភ្លើងក្រោមដីដែលមានស្តង់ដារខ្ពស់ជាងគេក្នុងការការពារអគ្គិភ័យ ។

រថភ្លើងក្រោមដីដែលផលិតដោយក្រុមហ៊ុន ស៊ីហ្វាង ក្រុងឈីងតាវទាំងនេះ នឹងត្រូវដាក់ឱ្យប្រើប្រាស់តាមខ្សែរថភ្លើងក្វាន់ថាង ឈួនវ៉ាន់កាងតាវនិងជាំងជូននៅតំបន់ហុងកុង ។ តាមផែនការដែលបានកំណត់ ក្រោយពីបានសាកល្បងរួចរាល់ រថភ្លើងក្រោមដីទី១ ដែលផលិតដោយក្រុមហ៊ុនស៊ីហ្វាង ក្រុងឈីងតាវ នឹងត្រូវដាក់ឱ្យប្រើប្រាស់ជាផ្លូវការក្នុងតំបន់ហុងកុងនៅឆមាសទី ២ នៃឆ្នាំ ២០១៨ ៕

**(ស៊ីនហួចិន)**